# ការរៀបការពារ ក្នុងរឿងក្ដីរដ្ឋប្បវេណី ផ្នែក 4

ថ្ងៃទី 25 ខែមេសា ឆ្នាំ2018
ជំនាញការនៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់
MAEDA Yuta

# ការធ្វើឧបាស្រ័យ

# ការតវ៉ាចំពោះការរក្សាការពារ

• ការតវ៉ាចំពោះការរក្សាការពារគឺជា
  វិធីនៃការធ្វើឧបាស្រ័យចំពោះដីកាសម្រេចរក្សាការពារ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា 550)

※ យ៉ាងណាមិញ ការធ្វើឧប្បាស្រ័យចំពោះដីកាសម្រេចលើកចោលពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារ ត្រូវធ្វើឡើងដោយបណ្ដឹងជំទាស់ (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា544 កថា.ទី1)។

នីតិវិធីដែលទាមទារឲ្យលុបចោលនូវការបង្គាប់ឲ្យរក្សាការពារ ដោយផ្អែកលើមូលហេតុនៃនត្ថិភាពនូវលក្ខខណ្ឌក្នុងការចេញការបង្គាប់ឲ្យរក្សាការពារធ្វើជាមូលហេតុ។

# ការតវ៉ាចំពោះការរក្សាការពារ

- អ្នកមានសិទ្ធិដាក់ពាក្យសុំ

 កូនបំណុលដែលទទួលបាននូវការបង្គាប់រក្សាការពារ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា 550)

- សមត្ថកិច្ច

 តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា550)

 ឧទា៖ ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារដែលសាលាដំបូងរាជធានីភ្នំពេញបានចេញ គឺត្រូវដាក់ពាក្យសុំទៅសាលាដំបូងរាជធានីភ្នំពេញ (មិនមែនតុលាការនៃបណ្តឹងឧទ្ធរណ៍ទេ។)។

# ការតវ៉ាចំពោះការក្សាការពារ

- ការវិនិច្ឆ័យ

ចាំបាច់ត្រូវឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា552)។

ដើម្បីអាចបញ្ចប់ការការវិនិច្ឆ័យបាន ចាំបាច់ត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យ ដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យ ឬ ត្រូវប្រកាសអំពីការបញ្ចប់ការវិនិច្ឆ័យ នៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា553)។

# ការតវ៉ាចំពោះការរក្សាការពារ

• ការវិនិច្ឆ័យ

ត្រឹមតែពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ មិនមានអានុភាព ផ្អាកនូវការអនុវត្តរក្សាការពារនោះទេ។

⇒ ដើម្បីផ្អាកនូវការអនុវត្តរក្សាការពារបាន ចាំបាច់ត្រូវដាក់ពាក្យសុំផ្អាកការអនុវត្ត (ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា551)។

# ការតវ៉ាចំពោះការរក្សាការពារ

- ដីកាសម្រេច

➢ដីកាសម្រេចចំពោះពាក្យសុំតវ៉ាដីកាសម្រេចរក្សាការពារ មាន 3 ប្រភេទគឺ 1.ការទទួលស្គាល់ (ករណីដែលរក្សានូវដីកាសម្រេចរក្សាការពារ) 2. ការផ្លាស់ប្តូរ 3. ការលុបចោល (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា554 កថា.ទី1)។

➢ តុលាការអាចដាក់លក្ខខណ្ឌឲ្យកូនបំណុលដាក់ប្រាតិភោគបាន ក្នុងករណីដែលសម្រេចថាលុបចោលនូវដីកាសម្រេចរក្សាការពារ (មាត្រាដដែល កថា.ទី2)។

# ការតវ៉ាចំពោះការរក្សាការពារ

- ដីកាសម្រេច

➢ នៅពេលដែលសម្រេចលុបចោលនូវដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន តុលាការអាចបង្គាប់ឲ្យធ្វើបដិទានបានតាមពាក្យសុំរបស់កូនបំណុល (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា555)។

➢ ដីកាសម្រេចដែលលុបចោលនូវដីកាសម្រេចរក្សាការពារ ពុំមានអានុភាពទេ បើមិនទាន់បានចូលជាស្ថាពរ ប៉ុន្តែ បើយល់ឃើញថា ចាំបាច់ពិសេស តុលាការអាចប្រកាសថា ដីកាសម្រេចនោះមានអានុភាពភ្លាមៗ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា556)។

# ការតវ៉ាចំពោះការរក្សាការពារ

- ដីកាសម្រេច

➢ ដីកាសម្រេចចំពោះពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ត្រូវតែបញ្ជូនទៅភាគី (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា554 កថា.ទី3 និង មាត្រា543)។

➢ អាចប្តឹងជំទាស់បាន ប្រសិនបើមានឧបាស្រ័យលើដីកាសម្រេចចំពោះពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា561 កថា.ទី1 ចំណុច ក. )។

# សេចក្តីសម្រេចបញ្ចប់នៃការតវ៉ារក្សាការពារ
# (ការទទួលស្គាល់)

1 ទទួលស្គាល់នូវដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន (ចាត់ចែងជាបណ្តោះអាសន្ន) ដែលតុលាការ.............បានចេញនៅថ្ងៃទី....ខែ.....ឆ្នាំ........ ស្តីអំពី "ឈ្មោះតុលាការ លេខសំណុំរឿង និង ឈ្មោះសំណុំរឿង" រវាងម្ចាស់បំណុល និងកូនបំណុល។

2 ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់កូនបំណុល។

# សេចក្ដីសម្រេចបញ្ចប់នៃការតវ៉ារក្សាការពារ
# ( ការលុបចោល )

1 លុបចោលនូវដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ( ចាត់ចែងជាបណ្ដោះអាសន្ន ) ដែលតុលាការ.............បានចេញនៅថ្ងៃទី....ខែ.....ឆ្នាំ........ ស្ដីអំពី "ឈ្មោះតុលាការ លេខសំណុំរឿង និង ឈ្មោះសំណុំរឿង" រវាងម្ចាស់បំណុល និងកូនបំណុល។

2 លើកចោលពាក្យសុំរឹបអូសជាបណ្ដោះអាសន្ន ( ចាត់ចែងជាបណ្ដោះអាសន្ន ) ខាងលើរបស់ម្ចាស់បំណុល។

3 ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ម្ចាស់បំណុល។

# ការលុបចោលនូវការរក្សាការពារ

- ប្រភេទនៃការលុបចោលការរក្សាការពារ

1. ការលុបចោលការរក្សាការពារដោយសារមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា 557)

2. ការលុបចោលការរក្សាការពារដោយសារការផ្លាស់ប្ដូរស្ថានភាព(ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា 558)

3. ការលុបចោលការរក្សាការពារដោយសារស្ថានភាពពិសេស (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា 559)

# ការលុបចោលនូវការរក្សាការពារ

1. ការលុបចោលនូវការរក្សាការពារដោយសារការមិនបានដាក់ពាក្យបណ្ដឹងអង្គសេចក្ដីជាអាទិ៍ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា 557)

- តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ត្រូវបង្គាប់ឲ្យម្ចាស់បំណុលដាក់ពាក្យបណ្ដឹងអង្គសេចក្ដី ហើយឲ្យដាក់ឯកសារបញ្ជាក់អំពីការដាក់ពាក្យបណ្ដឹងអង្គសេចក្ដីនោះ ដោយកំណត់អំឡុងពេលមិនតិចជាង២សប្ដាហ៍ តាមពាក្យសុំរបស់កូនបំណុល (កថា.ទី១ និង ទី២) ។

↓

- បើម្ចាស់បំណុលមិនដាក់ឯកសារដែលបានកំណត់ខាងលើនេះក្នុងពេលដែលបានកំណត់ទេ តុលាការត្រូវលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុល (កថា.ទី៣) ។ យ៉ាងណាមិញ ក្នុងករណីដែលពាក្យបណ្ដឹងអង្គសេចក្ដីត្រូវបានដកវិញ ឬ ត្រូវបានលើកចោល នៅក្រោយពេលដែលឯកសារដែលបានកំណត់ខាងលើត្រូវបានដាក់ ត្រូវចាត់ទុកថា ឯកសារនោះមិនបានដាក់ឡើយ (កថា.ទី4)។

# ការលុបចោលនូវការរក្សាការពារ

2. ការលុបចោលការរក្សាការពារដោយសារការផ្លាស់ប្តូរស្ថានភាព( ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា558 )

- សមត្ថកិច្ច

តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ឬ តុលាការនៃបណ្តឹងអង្គសេចក្តី

- លក្ខខណ្ឌ

ការរលត់នូវសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តិដែលនឹងត្រូវបានរក្សាការពារ ឬ ភាពចាំបាច់នៃការរក្សាការពារ និងស្ថានភាពផ្សេងទៀត

= នាពេលបច្ចុប្បន្នទាក់ទងនឹងសិទ្ធិដែលនឹងត្រូវបានរក្សាការពារ ឬ ភាពចាំបាច់នៃការរក្សាការពារ តុលាការបានចេញដីកាសម្រេចរក្សាការពារ

ករណីដែលគួរតែធ្វើការសម្រេចខុសពីនេះនៅពេលដែលចេញដីកាសម្រេចនោះ។

ឧទា៖ សាលក្រមដែលម្ចាស់បំណុលបានឈ្នះក្តីនៅក្នុងបណ្តឹងអង្គសេចក្តីបានចូលជាស្ថាពរ  សិទ្ធិដែលនឹងត្រូវបានរក្សាការពារត្រូវរលត់ដោយសារការសងជាអាទិ៍

# ការលុបចោលនូវការរក្សាការពារ

3. ការលុបចោលការរក្សាការពារដោយសារស្ថានភាពពិសេស (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា559)

- សមត្ថកិច្ច

  តុលាការដែលបានចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ឬ តុលាការនៃបណ្ដឹងអង្គសេចក្ដី

- លក្ខខណ្ឌ

  មានការបារម្ភថា ការខូចខាតដែលមិនអាចសងបាន នឹងកើតឡើងដោយសារដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ឬ មានស្ថានភាពពិសេសផ្សេងទៀត

- នៅពេលដែលចេញដីកាសម្រេច តុលាការត្រូវតែមានលក្ខខណ្ឌដែលតម្រូវឲ្យដាក់ប្រាតិភោគ។

# ការលុបចោលនូវការរក្សាការពារ

4. ការវិនិច្ឆ័យ និង ការចេញដីកាសម្រេចអំពីការលុបចោលនូវការរក្សាការពារ

វិធានស្តីអំពីការតវ៉ាចំពោះការរក្សាការពារ (លើកលែងតែ មាត្រា554 នៃក្រមនីតិវិធីរដ្ឋប្បវេណី ) ត្រូវបានយកមកអនុវត្ត (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា560) ។

※ ប៉ុន្តែ លើកលែង (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា560 កថា.ទី1 ករណីលើកលែង) នូវដីកាសម្រេចដែលបង្គាប់ឲ្យម្ចាស់បំណុលដាក់ពាក្យបណ្តឹងអង្គសេចក្តី ហើយឲ្យដាក់ឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្តឹងនោះ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា 557 កថា.ទី1)។

- មានភាពចាំបាច់ក្នុងការបញ្ជូន (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា557 កថា.ទី8 មាត្រា558 កថា.ទី3 មាត្រា559 កថា.ទី3 មាត្រា543) លើកលែងតែដីកាសម្រេចខាងលើ។
- អាចធ្វើបណ្តឹងជំទាស់បាន ប្រសិនបើមានការធ្វើឧបាស្រ័យលើដីកាសម្រេចនោះ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា561 កថា.ទី1 ចំណុច ក. )។

# សេចក្តីសម្រេចបញ្ចប់នៃការលុបចោលការក្សាការពារ (ធម្មតា)

1 លុបចោលនូវដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន (ចាត់ចែងជាបណ្តោះអាសន្ន) ដែលសាលាដំបូង..................បានចេញនៅថ្ងៃទី....ខែ.....ឆ្នាំ.......... ស្តីអំពី "លេខសំណុំរឿង និង ឈ្មោះសំណុំរឿង" នៃតុលាការនេះ។

2 ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់អ្នកដាក់ពាក្យសុំ។

# សេចក្តីសម្រេចបញ្ចប់នៃការលុបចោលការរក្សាការពារ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា 559)

1 លុបចោលនូវដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលសាលាដំបូង........បានចេញនៅថ្ងៃទី.....ខែ.........ឆ្នាំ................ស្តីពី "លេខសំណុំរឿង និង ឈ្មោះសំណុំរឿង"នៃតុលាការនេះ ដោយមានល័ក្ខខ័ណ្ឌតម្រូវឲ្យអ្នកដាក់ពាក្យសុំដាក់ប្រាតិភោគចំនួន..............ដុល្លារដើម្បីភាគីម្ខាងទៀត ក្នុងចន្លោះពីថ្ងៃបន្ទាប់នៃថ្ងៃដែលបានបញ្ជូនដីកាសម្រេចនេះរហូតដល់ត្រឹមថ្ងៃទី......... ។

2 ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីម្ខាងទៀត។

# បណ្តឹងជំទាស់

សេចក្តីសម្រេចដែលអាចឲ្យធ្វើបណ្តឹងជំទាស់បាន (ផ្នែក 1)

- ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ( លើកលែងពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារដែលតុលាការនៃបណ្តឹងជំទាស់បានចេញ ) ឬ ដីកាសម្រេចអំពីពាក្យសុំទាមទារឲ្យលុបចោលដីកាសម្រេចរក្សាការពារ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា561 កថា.ទី1 ចំណុច.ក) ។
- ដីកាសម្រេចដែលបង្គាប់ឲ្យធ្វើបដិទានក្នុងករណីដែលលុបចោលនូវដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា561 កថា.ទី1 ចំណុច ខ និង គ)
- ប្រុងប្រយ័ត្នទៅលើ ៖ អំឡុងពេលដែលអាចប្តឹងជំទាស់បានគឺ២សប្តាហ៍ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា 561 ខ្លឹមសារដំបូងនៃកថា.ទី1) មានភាពចាំបាច់នូវការទាញហេតុផលដោយផ្ទាល់មាត់ ឬ ការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា561 កថា.ទី3 មាត្រា552 មាត្រា553)។

# បណ្ដឹងជំទាស់

សេចក្ដីសម្រេចដែលអាចឲ្យធ្វើបណ្ដឹងជំទាស់បាន (ផ្នែក 2)

- សេចក្ដីសម្រេចដែលលើកចោលពាក្យសុំឲ្យចេញដីកាសម្រេចរក្សាការពារ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា544 កថា.ទី1)

ប្រុងប្រយ័ត្ននូវ អំឡុងពេលដែលអាចប្ដឹងជំទាស់បានគឺ 2សប្ដាហ៍ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា544 កថា.ទី1) ។ ចំពោះនីតិវិធីនេះវិញ គឺដូចគ្នានឹងករណីនៃបណ្ដឹងជំទាស់ធម្មតាដែរ ហើយមិនមានភាពចាំបាច់នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ឬ ការសួរទេ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា539 និង មាត្រា306)។

※ វិធីនៅក្នុងការវិនិច្ឆ័យមានលក្ខណៈខុសគ្នាពី បណ្ដឹងជំទាស់ចំពោះដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា 561)។